**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ១០៩៦ - អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងតំណាងជាតិទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការ មហាអនុតំបន់មេគង្គ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០១៣ អនក្រ.តត ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ
- បានឃើញអនុក្រឹត្យលេខ ៤៦៨ អនក្រ.តត ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានតែងតាំងនិងប្រគល់ភារកិច្ចបន្ថែមលើមុខងារបច្ចុប្បន្នជូនឥស្សរជន ដូចមានរាយនាមខាងក្រោម៖

១. ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជារដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

២. ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកសម្របសម្រួលជាតិ នៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងជាប្រធានលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ។

៣. ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកជំនួស ក្នុងករណីអវត្តមានឯកឧត្តមអ្នកសម្របសម្រួលជាតិ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ មានភារកិច្ចដូចតទៅ៖

ក. ទទួលខុសត្រូវក្នុងការសម្របសម្រួល និងដឹកនាំការងារក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ជាមួយនឹងប្រទេសជាសមាជិកដទៃទៀត និងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដៃគូអភិវឌ្ឍន៍ដទៃទៀតដែលមានការពាក់ព័ន្ធ។

ខ. ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ។

គ. ត្រួតពិនិត្យ តាមដាន និងបូកសរុបការអនុវត្តគម្រោងសហប្រតិបត្តិការនានានៅក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

ឃ. រាយការណ៍ជាប្រចាំ អំពីការងាររបស់ខ្លួន និងអំពីលទ្ធផលនៃកិច្ចប្រជុំនានាពាក់ព័ន្ធនឹងកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ជូននាយករដ្ឋមន្ត្រី-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាជ្រាប និងផ្តល់ការណែនាំ។

**មាត្រា ៣.-**

អ្នកសម្របសម្រួលជាតិនៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងជាប្រធានលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ មានភារកិច្ចដូចតទៅ៖

ក. ទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការអនុវត្តគម្រោងក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ។

ខ. ដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីមហាអនុតំបន់មេគង្គ និងកិច្ចប្រជុំពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គ។

គ. ដឹកនាំលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គដែលជាស្ថាប័ន "ច្រកចេញ-ចូលតែមួយ" សម្រាប់កិច្ចសហប្រតិបត្តិការ នៅក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ដើម្បីជួយដល់រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ក្នុងការបំពេញភារកិច្ចដូចមានចែងខាងលើ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ អ្នកសម្របសម្រួលជាតិនៃកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ និងលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ៥.-**

គ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើតអង្គភាពមហាអនុតំបន់មេគង្គ (GMS Unit) និង ដើម្បីទទួលបន្ទុកកិច្ចការក្នុងក្របខ័ណ្ឌកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ តាមសមត្ថកិច្ចរៀងខ្លួន។

**មាត្រា ៦.-**

ប្រធានអង្គភាពមហាអនុតំបន់មេគង្គរបស់ក្រសួង-ស្ថាប័ននីមួយៗគឺជាសមាជិករបស់លេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ។

**មាត្រា ៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី គ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ